ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

03.03.11

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១៥.សសរ

# សេចក្តីសម្រេច
## ស្តីពីការបង្កើតក្រុមការងាររៀបចំពាក្យបណ្តឹងបញ្ហាប្រាសាទព្រះវិហារ ទៅតុលាការយុត្តិធម៌អន្តរជាតិទីក្រុងឡាអេ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមតម្រូវការការងារចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ ១** ៖ ត្រូវបានបង្កើតក្រុមការងាររៀបចំពាក្យបណ្តឹងបញ្ហាប្រាសាទព្រះវិហារ ទៅតុលាការយុត្តិធម៌អន្តរជាតិទីក្រុងឡាអេ ដូចមានសមាសភាពខាងក្រោម ៖

| | | |
|---|---|---|
| ១-ឯកឧត្តម **ហោ ណាំហុង** | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | ប្រធាន |
| ២- ឯកឧត្តម **វ៉ា គឹមហុង** | ទេសរដ្ឋមន្ត្រី ទទួលបន្ទុកកិច្ចការព្រំដែននៃទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៣- ឯកឧត្តម **អួន ព័ន្ធមុនីរ័ត្ន** | រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ៤- ឯកឧត្តម **ឡុង វិសាលោ** | រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ៥- ឯកឧត្តម **អ៊ិជ គឹមអន** | ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពនៃព្រះរាជាណាចក្រកម្ពុជាប្រចាំសាធារណរដ្ឋបារាំង | សមាជិក |

**ប្រការ ២** ៖-ក្រុមការងារមានភារកិច្ច រៀបចំពាក្យបណ្តឹង និងឯកសារយោងទៅតុលាការយុត្តិធម៌អន្តរជាតិ ទីក្រុងឡាអេ ដើម្បីធ្វើការបកស្រាយសាលក្រមថ្ងៃទី ១៥ មិថុនា ១៩៦២ ។

-ក្រុមការងារអាចជ្រើសរើស និងជួលអ្នកច្បាប់បរទេស ព្រមទាំងចាត់វិធានការចាំបាច់នានា ដើម្បីធានាជោគជ័យនៃភារកិច្ចខាងលើ ។

-ក្រុមការងារត្រូវបន្តទំនាក់ទំនងការងារជាមួយតុលាការយុត្តិធម៌អន្តរជាតិស្របតាមនីតិវិធីរបស់តុលាការរហូតដល់ទទួលបានលទ្ធផលបញ្ចប់នៃការបកស្រាយសាលក្រមខាងលើ ។

-ប្រធានក្រុមការងារ អាចជ្រើសរើសមន្ត្រីមានសមត្ថកិច្ចផ្សេងៗទៀត ដើម្បីជួយដល់ក្រុមការងារ។

**ប្រការ ៣** ៖ ក្រុមការងារត្រូវរាយការណ៍ជូនសម្តេចនាយករដ្ឋមន្ត្រីអំពីការវិវត្តន៍នៃការងារនិងស្នើសុំការណែនាំតាមការចាំបាច់ ពីសម្តេចនាយករដ្ឋមន្ត្រី ។

**ប្រការ ៤**៖ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ មីនា ឆ្នាំ២០១១

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៤
- ឯកសារ-កាលប្បវត្តិ